ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

លេខ: ០០១ ១៧ ក.ជ.អ.ច.

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ ៖** របាយការណ៍ស្តីពីវឌ្ឍនភាពការងារនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-រុស្ស៊ីលើវិស័យបរិស្ថាន និងការប្រើប្រាស់ថាមពលនុយក្លេអ៊ែរសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព

**យោង ៖** លិខិតលេខ៦៣០៧ អរ.កបទ.សអ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា បន្ទាប់ពីរាជរដ្ឋាភិបាលអនុញ្ញាតជាគោលការណ៍ឱ្យក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព(ក.ជ.អ.ច.)ធ្វើការជាមួយសាជីវកម្មថាមពលបរមាណូរដ្ឋ(សហព័ន្ធរុស្ស៊ី) «Rosatom» ក្នុងកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់ថាមពលនុយក្លេអ៊ែរ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព ភាគីទាំងពីរបានចុះហត្ថលេខាជាបន្តបន្ទាប់លើឯកសារចំនួន៤គឺ៖ ១- អនុស្សរណៈនៃការយោគយល់ស្តីពីកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់ថាមពលបរមាណូសម្រាប់បម្រើឱ្យគោលបំណងសន្តិភាព (ភ្នំពេញ ២៤ វិច្ឆិកា ២០១៥) ២- អនុស្សរណៈនៃការយោគយល់ស្តីពីការបង្កើតក្រុមការងាររួមកម្ពុជា-រុស្ស៊ី សម្រាប់កិច្ចសហប្រតិបត្តិការ ក្នុងការប្រើប្រាស់ថាមពលបរមាណូ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព (ម៉ូស្គូ ១៧ ឧសភា ២០១៦) ៣- អនុស្សរណៈនៃការយោគយល់ស្តីពីការបង្កើតមជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ (ម៉ូស្គូ ១៧ ឧសភា ២០១៦) និង ៤- កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហព័ន្ធរុស្ស៊ីស្តីពីកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់ថាមពលបរមាណូ សម្រាប់បម្រើឱ្យគោលបំណងសន្តិភាព (វីយ៉ែន ១៩ កញ្ញា ២០១៧) ក្នុងឱកាសមហាសន្និបាតលើកទី៦១ នៃទីភ្នាក់ងារថាមពលអាតូមិកអន្តរជាតិ (IAEA)។ ក្រៅពីនេះ ភាគីកម្ពុជាក៏បានចុះហត្ថលេខាជាមួយសមភាគីរុស្ស៊ីលើ «អនុស្សរណៈនៃការយោគយល់រវាងក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងធនធានធម្មជាតិ និងបរិស្ថាននៃសហព័ន្ធរុស្ស៊ីស្តីពីកិច្ចសហប្រតិបត្តិការលើកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព» នៅទីក្រុងម៉ូស្គូ ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ ផងដែរ។

ការអនុវត្តកិច្ចព្រមព្រៀងទាំង៥ខាងលើនេះមានវឌ្ឍនភាពដូចខាងក្រោម៖

**១. កិច្ចសហប្រតិបត្តិការក្នុងវិស័យថាមពលនុយក្លេអ៊ែរ**

- បានរៀបចំកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ី ចំនួន២លើក ដើម្បីពិនិត្យ តាមដាន និងវាយតម្លៃដំណើរការនៃកិច្ចសហប្រតិបត្តិការទ្វេភាគី ដែលលើកទី១ ធ្វើនៅភ្នំពេញ (១៧ សីហា ២០១៦) និងលើកទី២នៅម៉ូស្គូ (២៧ កុម្ភៈ ២០១៨)។

- គណៈប្រតិភូកម្ពុជាបានចូលរួមវេទិកាអន្តរជាតិ AtomExpo ចំនួន៣លើក ដែលរៀបចំដោយភាគីរុស្ស៊ី Rosatom ដើម្បីស្វែងយល់អំពីបច្ចេកវិទ្យានិងឧស្សាហកម្មនុយក្លេអ៊ែរ និងដំណើរវិវឌ្ឍន៍របស់វា ដោយសង្កត់ធ្ងន់លើបញ្ហាសុវត្ថិភាព គុណភាពបរិស្ថាន និងការអភិវឌ្ឍដោយចីរភាព។
- ជំរុញដំណើរការរៀបចំបង្កើត «មជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ» នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) ដោយចាប់ផ្តើមពីសកម្មភាពមួយចំនួន ក្រោមផែនការអប់រំផ្សព្វផ្សាយរួមគ្នា៖
    - កិច្ចសហប្រតិបត្តិការរវាង ITC (កម្ពុជា) និង Rosatom South East Asia Pte Ltd, Singapore (បានចុះ MoU ឆ្នាំ២០១៨)
    - គម្រោងរៀបចំ«បាឋកថាស្តីពីបច្ចេកវិទ្យានុយក្លេអ៊ែរ» ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨ នៅ ITC
    - ការបកប្រែសៀវភៅអប់រំអំពីវិទ្យាសាស្ត្រនុយក្លេអ៊ែរ (Nuclear ABC) ជាភាសាខ្មែរ
    - ការត្រៀមចូលរួមរៀបចំ«ទិវាវិទ្យាសាស្ត្រនុយក្លេអ៊ែរ»
    - ការបង្កើតក្លឹបពិភាក្សាវែកញែកអំពីវិទ្យាសាស្ត្រនុយក្លេអ៊ែរ
    - ការបណ្តុះបណ្តាលអ្នកសារព័ត៌មានអំពីការសរសេរអត្ថបទព័ត៌មានវិទ្យាសាស្ត្រ។
- បានរៀបចំតារាងតម្រូវការរបស់ភាគីកម្ពុជា សម្រាប់ស្នើសុំភាគីរុស្ស៊ីឱ្យជួយអប់រំ និងបណ្តុះបណ្តាលក្នុងផែនការកសាងធនធានមនុស្ស។ ក្នុងឆ្នាំ២០១៧ យើងមាននិស្សិត២រូប សិក្សាថ្នាក់បរិញ្ញាបត្រជំនាញវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានុយក្លេអ៊ែរនៅសហព័ន្ធរុស្ស៊ី ហើយក្នុងឆ្នាំ២០១៨នេះ បេក្ខជននិស្សិតចំនួន៦រូប ត្រូវបានជ្រើសរើសឱ្យត្រៀមទៅសិក្សាថ្នាក់បរិញ្ញាបត្រនៅសហព័ន្ធរុស្ស៊ី។ ចំណែកការបណ្តុះបណ្តាលរយៈពេលខ្លីវិញ យើងបានបញ្ជូនមន្ត្រីជំនាញ១រូបឱ្យចូលរួមវគ្គបណ្តុះបណ្តាលនៅសហព័ន្ធរុស្ស៊ីក្នុងឆ្នាំ២០១៦ និងកំពុងត្រៀមបញ្ជូនមន្ត្រីជំនាញ១រូបទៀត ឱ្យចូលរួមវគ្គបណ្តុះបណ្តាលជំនាញស្រាវជ្រាវម៉ាស៊ីនប្រតិករ នៅសហព័ន្ធរុស្ស៊ី នាចុងឆ្នាំ២០១៨នេះ។
- បាននិងកំពុងពិនិត្យសេចក្តីព្រាង «កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលសហព័ន្ធរុស្ស៊ីស្តីពីកិច្ចសហប្រតិបត្តិការ ក្នុងការសាងសង់មជ្ឈមណ្ឌលវិទ្យាសាស្ត្រ និងបច្ចេកវិទ្យានុយក្លេអ៊ែរនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា» ដោយ៖
    - បានរៀបចំកិច្ចប្រជុំការងារបច្ចេកទេសកម្ពុជា-រុស្ស៊ីចំនួន៣លើក ដែលលើកទី១នៅម៉ូស្គូ (២៧ កុម្ភៈ ២០១៨) លើកទី២នៅភ្នំពេញ (២៥ មេសា ២០១៨) និងលើកទី៣ នៅភ្នំពេញ (២៨ សីហា ២០១៨)
    - បានរៀបចំកិច្ចប្រជុំផ្ទៃក្នុង (ក្រុមការងារថ្នាក់ជាតិភាគីកម្ពុជា) ចំនួន៦លើក ដើម្បីពិនិត្យសេចក្តីព្រាងកិច្ចព្រមព្រៀងនេះ និងបានប្រជុំពិភាក្សាការងារជាមួយក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី ហើយបច្ចុប្បន្នកំពុងប្រមូលផ្តុំធាតុចូលជាយោបល់បច្ចេកទេសនិងជំហរពីក្រសួងរ៉ែនិងថាមពល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជាមូលដ្ឋានសម្រាប់កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ មុននឹងដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

## ២. កិច្ចសហប្រតិបត្តិការក្នុងវិស័យបរិស្ថាន

«អនុស្សរណៈនៃការយោគយល់រវាងក្រសួងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងធនធានធម្មជាតិនិងបរិស្ថាននៃសហព័ន្ធរុស្ស៊ី ស្តីពីកិច្ចសហប្រតិបត្តិការលើកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការអភិវឌ្ឍដោយចីរភាព» ត្រូវបានចុះហត្ថលេខាដោយឯកឧត្តម

**អ៊ុច បូរិទ្ធ** រដ្ឋលេខាធិការនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ តំណាងឱ្យភាគីកម្ពុជា នៅម៉ូស្គូ នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧។ នៅថ្ងៃបន្ទាប់ ឯកឧត្តម **អ៊ាង សុផល្លែត** អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន រួមជាមួយគណៈប្រតិភូអមបានជួបប្រជុំជាមួយសមភាគីរុស្ស៊ីនៅទីក្រុងម៉ូស្គូ ដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការ ដោយត្រូវចាប់ផ្តើមពីកិច្ចប្រជុំក្រុមការងារបច្ចេកទេសរវាងក្រសួងបរិស្ថាននៃប្រទេសទាំងពីរ។

## ៣. ទិសដៅការងារ

ក. រៀបចំកិច្ចប្រជុំក្រុមការងាររួមកម្ពុជា-រុស្ស៊ីលើកទី៣ នៅកម្ពុជា ក្នុងខែវិច្ឆិកា ឆ្នាំ២០១៨។
ខ. រៀបចំកិច្ចប្រជុំក្រុមការងារបរិស្ថានលើកទី១ នៅទីក្រុងម៉ូស្គូ ក្នុងខែវិច្ឆិកាឆ្នាំ២០១៨។
គ. បន្តជំរុញការបង្កើត «មជ្ឈមណ្ឌលព័ត៌មានថាមពលនុយក្លេអ៊ែរ» នៅរាជធានីភ្នំពេញ (ITC)។
ឃ. បន្តជំរុញការកសាងធនធានមនុស្សក្នុងវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានុយក្លេអ៊ែរ។
ង. បញ្ចប់ការពិនិត្យសេចក្តីព្រាង«កិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលសហព័ន្ធរុស្ស៊ីស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសាងសង់មជ្ឈមណ្ឌលវិទ្យាសាស្ត្រនិងបច្ចេកវិទ្យានុយក្លេអ៊ែរនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា» ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យនិងសម្រេច។

## ៤. យោបល់ និងសំណើ

គោរពស្នើសុំរៀបចំជំនួបទ្វេភាគីរវាងថ្នាក់ដឹកនាំក្រសួងបរិស្ថាននៃប្រទេសទាំងពីរ ក្នុងឱកាស ដែលឯកឧត្តម Dmitry Kobylkin រដ្ឋមន្ត្រីក្រសួងធនធានធម្មជាតិនិងបរិស្ថាននៃសហព័ន្ធរុស្ស៊ីអញ្ជើញចូលរួមក្នុងកិច្ចប្រជុំសហប្រធាននៃគណៈកម្មការអន្តររដ្ឋាភិបាលកម្ពុជា-រុស្ស៊ីស្តីពីកិច្ចសហប្រតិបត្តិការពាណិជ្ជកម្ម សេដ្ឋកិច្ច វិទ្យាសាស្ត្រ និងបច្ចេកទេស ដែលរៀបចំដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ។

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជាព័ត៌មាន ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ថ្ងៃ អង្គារ ១ រោច ខែ ភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៨

**ប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព**

**និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**